# ការរៀបចំខ្លួនសំរាប់ពេលមានអាសន្ន

Emergency Preparedness
WUML
9/9/07

អស់លោក-លោកស្រី ប្រសិនបើមានអាសន្នអ្វីមួយកើតឡើង តើអស់លោក-លោកស្រីបាន រៀបចំខ្លួន ស្រេចបាច់ហើយ ឬនៅ?

ខែកញ្ញាឆ្នាំ 2007 នេះ ជាខួបទីបួននៃការធ្វើកម្មវិធីដើម្បីរៀបចំ អនុវត្ត នៅពេលមានអាសន្ន ទូទាំងសហរដ្ឋ ហៅថា National Emergency Preparedness Month ដែលរៀបចំឡើង ដោយក្រសួងរក្សាសន្តិសុខនៃសហរដ្ឋ ពាក្យអង់គ្លេសហៅថា Department of Homeland Security។  គោលបំណង់មួយ របស់ក្រសួងរក្សាសន្តិសុខនៃសហរដ្ឋគឺ ដើម្បីអប់រំសាធារណៈ ជនទាំងអស់ ឲ្យមានលទ្ធភាពអាចអនុវត្ត ឆ្លើយតបទៅនឹងភាពអាសន្នម្តងៗ រួមទាំង គ្រោះថ្នាក់ ដែលបណ្តាលមកពីធម្មជាតិ ដូចជាខ្យល់ព្យុះនិងទឹកលេច, គ្រោះថ្នាក់របួសរង្កាល ដូចជាការឆ្លង មេរោគឬរលាកជាតិគីមី, ការប៉ះកម្មរស្មីនិងអំពីវិច្ឆេទកម្មផ្សេងៗ។

ជាមួយគ្នានេះ នៅទូទាំងសហរដ្ឋទាំងមូល មានធ្វើពិធីជាច្រើន ដើម្បីជួយរៀបចំពលរដ្ឋទាំង អស់ ឲ្យហ្វាត់ហ្វឹកហ្វឺន ដើម្បីត្រៀមខ្លួន ក្នុងករណីដែលមានអាសន្នម្តងៗ។ អង្គការណ៍ទាំង អស់ ចំនួនប្រហែលជា 1,300 ក្នុងសហរដ្ឋទាំងមូល, តាមរដ្ឋនីមួយៗ និងតាមតំបន់នានា បាន រៀបចំ ហាត់ហ្វឹកហ្វឺន ដើម្បីធ្វើអន្តរាគមន៍នៅពេលមានអាសន្ន។

អស់លោក-លោកស្រីអាចចូលរួម ក្នុងការហាត់ហ្វឹកហ្វឺននេះបាន ដោយរៀបចំជា៖

- ប្រអប់ ឬគេះសំរាប់ដាក់គ្រឿងដែលត្រូវប្រើប្រាស់
- រៀបចំជាគំរោងការណ៍សំរាប់អនុវត្ត និង
- ឧស្សាហ៍ស្តាប់ពត៌មានផ្សេងៗ ដើម្បីឲ្យបានជ្រាបអំពីហេតុការណ៍ ដែលអាចកើតមាន

ប្រអប់ឬកេះសំរាប់ដាក់គ្រឿងដែលត្រូវប្រើប្រាស់ គួរមានដាក់របស់ ដូចជា ទឹកនិងម្ហូបជាដើម។ លោកអ្នកគួរ សំរាំងរបស់ទាំងនេះសំរាប់ប្រើក្នុងរយៈពេល យ៉ាងហោចណាស់ឲ្យបានប្រហែល បីថ្ងៃ។

ក្នុងការរៀបចំគំរោងការណ៍សំរាប់អនុវត្ត នៅពេលមានអាសន្ន គឺលោកអ្នកគួរពិគ្រោះ សន្យា ណាត់ ជាមួយសមាជិកក្នុងគ្រួសារនិងញាតិមិត្រ ឲ្យដឹងគ្នា ថាតើត្រូវធ្វើយ៉ាងដូចម្តេច ប្រសិន

បើមានអាសន្ន ហើយពេលនោះលោកអ្នកនៅពុំជុំគ្នា។ សូមជជែកពិគ្រោះ អំពីវិធីដែលត្រូវទាក់ទងគ្នា, កន្លែងដែលត្រូវជួបគ្នា, និងវិធីដែលត្រូវអនុវត្តទៅតាមកាលទេសៈ ឬស្ថានការណ៍នីមួយៗ។

សាកសួរកន្លែងដែលលោកអ្នកធ្វើការនិងសាលា ដែលកូនរៀន អំពីគំរោងការណ៍អនុវត្តនៅពេលមានអាសន្ន។ កន្លែងធ្វើការទាំងរោងចក្រធំៗ, Company តូចៗ, និងក្រសួងសិក្សាធិការ គួរមានហាត់ហ្វឹកហ្វឺន អំពីវិធីអនុវត្តន៍នៅពេលអាសន្នម្តងៗ។

ក្នុងការជ្រាបពត៌មាន អំពីហេតុការណ៍ផ្សេងៗ ដែលអាចកើតមានឡើង លោកអ្នកគួរចាំស្តាប់និងមើលព្រឹត្តការណ៍តាមវិទ្យុ, តាមទូរទស្សន, តាមកាសែត, ទាក់ទងគ្នាទៅវិញទៅមក តាមទូរស័ព្ទដៃ ឬទូរស័ព្ទនៅផ្ទះ ដើម្បីឲ្យដឹងច្បាស់អំពីព្រឹត្តការណ៍និងអំពីដំណឹងផ្សេងៗ ដែលត្រូវអនុត្ត។

នៅពេលមានអាសន្នម្តងៗ ការិយាល័យចាត់ចែងការណ៍សំរាប់ពេលអាសន្ន ហៅថា Emergency Management ឬ Emergency Services office នឹងផ្តល់ពត៌មានដល់សាធារណៈជន អំពីកន្លែងសំរាប់ទៅជ្រកកោន និងផ្លូវដែលត្រូវជន្លៀស ប្រសិនបើត្រូវការចាំបាច់។

ចំណែកមួយនៃការរៀបចំខ្លួនក្នុងការរៀបចំអនុវត្តនៅពេលមានអាសន្នទូទាំងសហរដ្ឋនេះ មជ្ឈមណ្ឌលការពារនិងបង្រ្កាបជម្ងឺ, Center for Disease Control and Prevention, ឬ CDC ក៏បានរៀបចំបង្កើតជាវិបសៃអិនធឺណិតមួយ ហៅថា ការរៀបចំខ្លួនសំរាប់ពេលអាសន្ននិងអ្នក, Emergency Preparedness and You។ មជ្ឈមណ្ឌល CDC បានធ្វើសហការណ៍ជាមួយក្រសួងកាកបាទក្រហមអាមេរិកាំង, American Red Cross ដើម្បីឲ្យដឹង និងដើម្បី ឆ្លើយនូវសំណួរទាំងឡាយ ទាក់ទងទៅនិងព្រឹត្តការណ៍ផ្សេងៗ ដែលកើតឡើងដោយ ពុំបានចាប់ភ្លឹកឬគ្រោងទុក ជាមុន។ ពត៌មានទាំងនេះ អាចជួយជាជំនួយដល់លោកអ្នក ឲ្យ៖

- រៀបចំខ្លួនសំរាប់គ្រួសារនៅពេលអាសន្ន
- រៀបចំគ្រឿងឧបរករណ៍ផ្សេងៗ សំរាប់ប្រើក្នុងកំឡុងពេលអាសន្ន
- រៀបចំជាជំរកសំរាប់ជ្រក
- ជ្រាបអំពីការដាក់ដោយឡែក នៅពេលមានការឆ្លងមេរោគ ហៅថា quarantine ឬ Isolation។
- ជ្រាបអំពីវិធីសំរាប់រក្សាអារម្មណ៍និងផ្លូវចិត្តឲ្យរឹងមាំនៅពេលមានអាសន្ន

បន្ថែមពីលើវិបសៃនេះ លោកអ្នកអាចចូលរួមជាមួយការហាត់ហ្វឹកហ្វឺនផ្សេងៗ នៅតាមសហគមន៍ និងចុះឈ្មោះស្មគ្រចិត្តជួយកិច្ចការសង្គ្រោះ នៅពេលណាដែលមានអាសន្នម្តងៗ។ ការធ្វើយ៉ាងដូច្នេះ អាចជួយឲ្យសហគមន៍មានកម្លាំងមាំមួន, មានសន្តិសុខ, និងអាចឆ្លើយតាមទៅនឹងស្ថានការណ៍អាសន្នចាំបាច់បាន។

ចំពោះពត៌មានបន្ថែម ក្រសួងរក្សាសន្តិសុខនៃសហរដ្ឋ, Department of Homeland Security មានតែងជាបញ្ជី, កូនសៀវភៅ, និង វីដេអូ សំរាប់មើលដើម្បីអនុវត្តនៅពេលអាសន្ន។ សូមមេត្តាទូរស័ព្ទទៅ 1-800-BE-READY ឬ 1-800-237-3239។ ឬអានវិបសៃរបស់មជ្ឈមណ្ឌលការពារនិងបង្រ្កាបជម្ងឺ, ការិល័យចាត់ចែងខាងការរៀបចំខ្លួនសំរាប់អនុវត្ត នៅពេលមានអំពើវិច្ឆេទកម្មនិងអាសន្ន Center for Disease Control and Prevention Coordinating Office for Terrorism Preparedness and Emergency Response ដែលមាន អាសយដ្ឋាន www.cdc.gov ។

National Prepareness Month: www.ready.gov